ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភារដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣៤៩

ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧

សាលដីកា

លេខ ១៤៨

ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ម៉ែន ស៊ុន ជាចៅក្រម

៣- លោក ទៀល ធួន ជាចៅក្រម

៤- លោក ស៊ុន ឌឹម ជាចៅក្រមរាយការណ៍

៥- លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា ហេន សុខា

តំណាងមហាអយ្យការ

លោក ម៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៥១៩ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦៥៣ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩២ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ឌឹម គឹមសិន ភេទប្រុស អាយុ ៤១ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅ ផ្ទះលេខ ៥៣ ផ្លូវលេខ ៣៥២ សង្កាត់ បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

និង ចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ រស់ គង់ ភេទប្រុស អាយុ ៥០ ឆ្នាំ ជាតិខ្មែរ មុខរបរ ប្រធាន នាយកដ្ឋានច្បាប់ និង កុងតិស្យុង នៃក្រសួងការបរទេស មានទីលំនៅ ផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ ក្រុង ភ្នំពេញ ។ " លោក រស់ គង់ តំណាងអោយក្រសួងការបរទេស " ។

កម្មវត្ថុបណ្តឹង: ប្តឹងសុំទោយភាពកិច្ចសន្យា .

បានឃើញបណ្តឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី៦ ខែ តុលា ឆ្នាំ ១៩៩៧ របស់ លោក ឌឹម គឹមសិន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥១៩ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ១៩៩៧ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងស្រុង ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤៩ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៤.១២.៩៤ របស់ក្រសួងការបរទេស បានប្តឹងសុំដកហូតដី និង ផ្ទះអតីតស្ថានទូតឡាវ និង សុំទាមទារថ្លៃឈ្នួលដី និង ផ្ទះ ដោយមូលហេតុឈ្មោះ ឌឹម គឹមសិន បានជួលពីក្រសួងការបរទេស ហើយពុំបានបង់ប្រាក់ឈ្នួលតាមកិច្ចសន្យាទេឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៨ "ព" ចុះថ្ងៃទី ១៨.០១.៩៦ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ១៩៩៤ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់លិខិតប្រគល់សិទ្ធិរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ លេខ ៦៧៤ក.ទកបទសអ ចុះថ្ងៃទី ៣០.០១.៩៥ អោយមកលោកឡុង ផល ជាតំណាង និង ជាដើមចោទក្នុងការប្តឹងទាមទារដី និង ផ្ទះពីឈ្មោះ ឌឹម គឹមសិន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- ទទួលពាក្យបណ្តឹងតបរបស់ឈ្មោះ ឌឹម គឹមសិន ជាចុងចម្លើយ ចុះថ្ងៃទី ១៤.០២.១៩៩៥ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្លូវនិងគតិច្បាប់ ។

៤- រំលាយចោលកិច្ចសន្យាជួលស្ថាទីម ចុះថ្ងៃទី ២៤.៨.៩២ និង កិច្ចសន្យាជួលដី ចុះថ្ងៃទី ២៥.៩.៩២ រវាងក្រសួងការបរទេស និង ឈ្មោះ ឌឹម គឹមសិន ចោលជាអសារបង់ ចាប់តាំងពីថ្ងៃនេះតទៅ តាមបញ្ញត្តិមាត្រា ១០៧ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី ២៨.១០.៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៥- ប្រគល់ភូមិគ្រឹះលេខ ១១១.១១៣ និង លេខ ៧៧ ផ្លូវ ២១៤ អតីតស្ថានទូតឡាវ និង ដីឡូតិ៍លេខ ១១៥ ផ្លូវសន្តិភាព ដែលជាកម្មសិទ្ធិរបស់ក្រសួងការបរទេស អោយទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដើម្បីកាន់កាប់ជាកម្មសិទ្ធិតទៅ ។

៦- បង្គាប់អោយឈ្មោះ ឌឹម គឹមសិន សងប្រាក់ថ្លៃឈ្នួលផ្ទះ និង ដីអោយទៅក្រសួងការបរទេស ចំនួន ២១០.៥០០ដុល្លាអាមេរិច "ពីររយដប់ពាន់ ប្រាំរយដុល្លាអាមេរិច" និង ជំងឺចិត្ត ចំនួន ៣.០០០ដុល្លាអាមេរិច "បីពាន់ដុល្លាអាមេរិច" សំណូមពរលើសពីនេះបដិសេធចោល ។

៧- បង្គាប់អោយឈ្មោះ ឌឹម គឹមសិន បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីការពិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល បូករួម ៧០០០រៀល ប្រាក់នេះកាត់ប្រាក់ដែលដើមចោទបង់ទុករួចហើយ កាលបើផុតកំណត់បណ្តឹងឧទ្ធរណ៍ បង្គាប់អោយឈ្មោះ ឌឹម គឹមសិន សងប្រាក់ ៧.០០០រៀលទៅដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រមួយភាគរយលើទឹកប្រាក់ ចំនួន២១៣.៥០០ដុល្លាអាមេរិច ស្មើ ២.១៣៥ដុល្លាអាមេរិច "ពីរពាន់មួយរយសាមសិបប្រាំដុល្លាអាមេរិច" ត្រូវបង់ចូលថវិការដ្ឋ៨០ភាគរយ ស្មើ ១៧០៨ដុល្លាអាមេរិច "មួយពាន់ប្រាំពីររយប្រាំបីដុល្លាអាមេរិច" រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយស្មើ ៤២៧ដុល្លាអាមេរិច "បួនរយម្ភៃប្រាំពីរដុល្លា" ។

ពន្ធសមាមាត្រនេះត្រូវអោយដើមចោទ បង់ទុកជាមុនសិនទើបអោយចុងចម្លើយ សងវិញជាក្រោយ ។

៨_ សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍រយៈពេល ៦០ថ្ងៃ ចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៩ "ខ" ចុះថ្ងៃទី ០៦.៣.៨៦ របស់លោក ឌឹម គឹមសិន ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ១៨ "ឃ" ចុះថ្ងៃទី១៨.០១.៨៦ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥១៩ ចុះថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ១៩៨៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :_

១_ ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៦.០៣.៨៦ របស់ឈ្មោះ ឌឹម គឹមសិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលក្រមលេខ ៨ "ឃ" ចុះថ្ងៃទី១៨.០១.៨៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣_ ទីបន្ទាល់ប្រាក់ប្រដាប់ក្តីដាក់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០ រៀល ដែលឈ្មោះ ឌឹម គឹមសិន បានបង់រួចហើយ ក្នុងនោះពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ចំនួន ២៨៥០ រៀល ទង្វាន់ក្រឡាបញ្ជីការនិពន្ធប្រាក់ ចំនួន ៤៥០ រៀល ទង្វាន់ស្នាក់ប្រគល់ដីកាកោះ ចំនួន ៥១០០ រៀល និង ចំណាយលើអាផ្ទាខតុលាការ ចំនួន ៥០០០ រៀល សរុប ១៣.០០០ រៀល ។

៤_ សាលដីកានេះប្រកាសជាសាធារណៈចំពោះមុខតំណាងក្រសួងការបរទេសឈ្មោះ ទស់ គង់ ក្បាំងមុខ ឌឹម គឹមសិន បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី០៧ ខែ តុលា ឆ្នាំ ១៩៨៧ របស់លោកឌឹម គឹមសិន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥១៩ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៨៧ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ០៦.០១.៨៨ របស់ឈ្មោះ ឌឹម គឹមសិន ។

បានឃើញសារណាតប ចុះថ្ងៃទី ២០.០២.៨៨ របស់ឈ្មោះ ទស់ គង់ "តំណាងអោយក្រសួងការបរទេស" ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការ :_

សាលដីការដ្ឋប្បវេណីលេខ ៥១៩ ចុះថ្ងៃទី ០៨.៩.៨៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុនេះស្នើក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់តទៅ ។

ក្រឡាបញ្ជីទទួលបានសារណារបស់ឈ្មោះ ឌឹម គឹមសិន ជាចុងចម្លើយ និង ជាដើមបណ្តឹងសាទុក្ខ

បានស្តាប់ចម្លើយរបស់ឈ្មោះ ទេព គង់ ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា: ការចោទរបស់លោក ឌិម គីមស៊ិន គឺភូតភរទាំងស្រុង ព្រោះក្នុងកិច្ចសន្យាជួល ចុះថ្ងៃទី ២៤.៥.៩២ លោក ឌិម គីមស៊ិន ធ្វើការជួលផ្ទះទុកសំភារៈលេខ ១១១ និង ១១៣ នៅផ្លូវលេខ៦១៤ និង ផ្ទះលេខ ៣៣ នៅផ្លូវលេខ ១៤១ ដែលគិតថ្លៃក្នុងរយៈពេល ៤ខែដំបូង ។ ពេលនោះ លោកឌិមគីមស៊ិន បានបង់ថ្លៃឈ្នួល ៦ខែដំបូង និងតែម្តងគត់ចំនួន ៤៨.០០០ដុល្លារអាមេរិច នៅថ្ងៃទី ០១.១០.៩២ បន្ទាប់មកលែងបង់ថ្លៃឈ្នួលទៀត ។ កិច្ចសន្យាជួល ថ្ងៃទី ២៥.៩.៩២ លោក ឌិម គីមស៊ិន ធ្វើការសាងសង់អាគារលើដីឡូតិ៍លេខ ១១៤ ដោយគិតថ្លៃឈ្នួលរយៈពេល ៤ខែ ក្រោយថ្ងៃចុះហត្ថលេខា និង នៅថ្ងៃទី០៤.៥.៩៣ បានបង់ចំនួន ៣៤០០ដុល្លារអាមេរិច សំរាប់ ៣ខែ ។ បន្ទាប់ពីនោះលែងបង់ឈ្នួលទៀត ហើយការលើកឡើងថា ជួសជុល និង ទិញសំភារៈអស់ប្រាក់ ចំនួន ១០.០០០ដុល្លារអាមេរិច គឺមិនពិតទេ ហើយចំពោះបញ្ហាមិនឲ្យមកស្នាក់នៅផ្ទះលេខ ៣៣ ទៀតនោះ ក្រសួងពុំដែលបានទទួលពាក្យបណ្តឹងពីលោក ឌិម គីមស៊ិន ទេ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់លោក ឌិម គីមស៊ិន ចម្លើយរបស់លោកទេព គង់ តំណាងឲ្យក្រសួងការបរទេស
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

## តុលាការកំពូល

៙៙៙៙៙៙៙៙៙៙៙

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣២៥ ចុះថ្ងៃទី ០៧.១០.៩៦ របស់លោក ឌិម គីមស៊ិន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា លោក ឌិម គីមស៊ិន ពិតជាបានជួលផ្ទះ និង ដីពីក្រសួងការបរទេសតាមកិច្ចសន្យា ចុះថ្ងៃទី ២៤.៥.៩២ និង ចុះថ្ងៃទី ២៥.៩.៩២ ហើយមិនទាន់បានបង់ប្រាក់ ថ្លៃឈ្នួលគ្រប់ចំនួន ឲ្យក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ប្រាកដមែន ។

- យល់ឃើញថា ខ្លឹមសារនៃសារណា ចុះថ្ងៃទី ០៦.០១.៩៨ របស់លោកឌិម គីមស៊ិន ដែលលើកឡើងថា តាំងពីខ្លួនជួលភូមិគ្រឹះ និង ដីរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មកខ្លួនបានជួសជុលអស់ទឹកប្រាក់ចំនួន ១០ម៉ឺនដុល្លារអាមេរិក ហើយពុំទាន់បានដំណើរការធ្វើអាជីវកម្មផងស្រាប់តែមានរាជរដ្ឋាភិបាលដកយកភូមិគ្រឹះទាំងនោះ ធ្វើជាព្រះវិហារនាំឲ្យរាំងស្ទះដល់អាជីវកម្មរបស់ខ្លួននោះ ជាការពុំត្រឹមត្រូវទេឡើយ ពីព្រោះថា ភូមិគ្រឹះទាំងនោះស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន តាមកិច្ចសន្យាជួលចែងខាងលើ ដូចនេះខ្លួនជាអ្នកទទួលខុសត្រូវទាំងស្រុង ។ ឯការអះអាងថាខ្លួនបានជួសជុលអស់ប្រាក់ចំនួន១០ម៉ឺនដុល្លារអាមេរិក ក៏ពុំមានភស្តុតាងបញ្ជាក់ដែរ ។

- យល់ឃើញថា លោក ងីម គីមស៊ិន បានធ្វើសារណាការពារទៅរឿងក្តីរបស់លោកជូនមក តុលាការកំពូល រួចហើយ ប៉ុន្តែលោកពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះទៅរឿង នេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ហើយពាក្យសុំពន្យារពេលសវនាការរបស់លោកតុលាការកំពូល ពុំអាចអនុញ្ញាតអោយបានទេឡើយ ពីព្រោះពុំមានមូលហេតុគ្រប់គ្រាន់ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៥១៩ ចុះថ្ងៃទី ០៨.៩.៥៧ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខលោក រស់ គង់ តំណាងក្រសួងការបរទេស
កំបាំងមុខលោក ងីម គីមស៊ិន ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៥៧ របស់លោក ងីម គីមស៊ិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៥១៩ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៥៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងអស់ ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដែលក្រសួងការបរទេស បានបង់ជួសលោក ងីម គីមស៊ិន នៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ:-

- ពន្ធចុះបញ្ជីក្តី និង ពន្ធត្រា ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៩០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីការពីប្រាក់ ។

- ចំណាយក្នុងការប្រកាសដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយត្រូវអោយលោក ងីម គីមស៊ិន សងប្រាក់ ចំនួន១៩.០០០រៀលនេះទៅក្រសួងការបរទេស វិញ ។

បង្គាប់អោយលោក ងីម គីមស៊ិន បង់ពន្ធមហាទារុណ តាមការកំណត់របស់តុលាការក្រុង ភ្នំពេញ ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៥៨ ។